ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧.០១៦.០០៣...ស.រ.ណ.ន

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១៦

# សារាចរណែនាំ

## ស្តីពី

## ការអនុវត្តប្រកាសស្តីពី

## ដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

យោងតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលត្រូវបានដាក់ឲ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ និងប្រកាសលេខ ធ៧-០១៦-១១៧ ប្រ.ក ស្តីពីដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ ធនាគារជាតិនៃកម្ពុជាកំណត់នីតិវិធីបង្កើនដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដូចខាងក្រោម ៖

### ១. ដើមទុនចុះបញ្ជីអប្បបរមា

#### ១.១ ធនាគារពាណិជ្ជជាសាខាធនាគារបរទេស

ធនាគារពាណិជ្ជដែលត្រូវបានបង្កើតឡើងក្រោមរូបភាពជាសាខាធនាគារបរទេសត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើនឹង ២០០.០០០.០០០.០០០ រៀល (ពីររយប៊ីលានរៀល) ប្រសិនបើធនាគារមេមាន "ចំណាត់ថ្នាក់វិនិយោគ" ។ សាខាធនាគារបរទេសផ្សេងទៀតដែលធនាគារមេមិនមានចំណាត់ថ្នាក់វិនិយោគត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើនឹង ៣០០.០០០.០០០.០០០រៀល (បីរយប៊ីលានរៀល) ។

"ចំណាត់ថ្នាក់វិនិយោគ" របស់ធនាគារមេត្រូវបានផ្តល់ដោយភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិយ៉ាងតិចចំនួនមួយក្នុងចំណោមភ្នាក់ងារចាត់ថ្នាក់ដូចជា៖ Moody's Investor Services, Standard & Poor's, Fitch ឬភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិផ្សេងទៀតដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា ។ "ចំណាត់ថ្នាក់វិនិយោគ" សំដៅលើចំណាត់ថ្នាក់ដែលស្មើ ឬខ្ពស់ជាង ៖

- Baa3 របស់ Moody's Investor Services
- BBB- របស់ Standard & Poor's និង
- BBB- របស់ Fitch។

លិខិតបញ្ជាក់អំពីចំណាត់ថ្នាក់ត្រូវមានសុពលភាព១ឆ្នាំ គិតមកដល់កាលបរិច្ឆេទរាយការណ៍មកធនាគារជាតិនៃកម្ពុជា ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

### ១.២ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្សេងទៀត

ចំពោះធនាគារពាណិជ្ជដែលត្រូវបានបង្កើតឡើងក្រោមរូបភាពជាបុត្តសម្ព័ន្ធធនាគារបរទេស ទោះបីធនាគារមេទទួលបានចំណាត់ថ្នាក់វិនិយោគ និង/ឬកាន់កាប់ភាគហ៊ុន១០០% ក៏ដោយ ត្រូវមានដើមទុនចុះបញ្ជីអប្បបរមា ស្មើនឹង ៣០០.០០០.០០០.០០០ រៀល (បីរយប៊ីលានរៀល) ។

ចំពោះធនាគារពាណិជ្ជ និងធនាគារឯកទេស ដែលត្រូវបានបង្កើតឡើងក្រោមរូបភាពជាក្រុមហ៊ុនក្នុងស្រុក គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវមានដើមទុនចុះបញ្ជីអប្បបរមាដូចមានចែងក្នុងខ្លឹមសារនៃប្រកាសស្តីពីដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដោយមិនគិតពីចំណាត់ថ្នាក់វិនិយោគ ។

## ២. រយៈពេលបង្កើនដើមទុន

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបង្កើនដើមទុនចុះបញ្ជីអប្បបរមាតាមការកំណត់ ដូចខាងក្រោម ៖

- ត្រូវបង្កើនដើមទុនចុះបញ្ជីអប្បបរមា ឲ្យបានយ៉ាងតិចពាក់កណ្តាលនៃដើមទុនដែលត្រូវបំពេញបន្ថែម យ៉ាងយូរបំផុតត្រឹមដំណាច់ខែមីនា ឆ្នាំ២០១៧ និង
- ត្រូវបង្កើនដើមទុនចុះបញ្ជីអប្បបរមាឲ្យបានគ្រប់ចំនួន យ៉ាងយូរបំផុតត្រឹមថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨ ។

## ៣. ឯកសារដែលត្រូវផ្តល់

សាខាធនាគារបរទេស និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្សេងទៀត ត្រូវផ្តល់ឯកសារជូនធនាគារជាតិនៃកម្ពុជា ក្នុងរយៈពេលមិនលើសពី៦ខែ បន្ទាប់ពីកាលបរិច្ឆេទចុះហត្ថលេខាលើសារាចរណែនាំនេះ ។

### ៣.១ សាខាធនាគារបរទេស ត្រូវផ្តល់ឯកសារដូចខាងក្រោម ៖

- ច្បាប់ចម្លងនៃសេចក្តីសម្រេចអំពីការបង្កើនដើមទុនចុះបញ្ជីរបស់ក្រុមប្រឹក្សាភិបាលនៃធនាគារមេ ឬបុគ្គលដែលបានទទួលសិទ្ធិពីក្រុមប្រឹក្សាភិបាលនៃធនាគារមេ
- លិខិតបញ្ជាក់អំពីចំណាត់ថ្នាក់របស់ធនាគារមេ
- លិខិតធានារបស់ធនាគារមេក្នុងការបង្កើនដើមទុនចុះបញ្ជីអប្បបរមា
- លិខិតធានាអំពីការបង្កើនដើមទុនចុះបញ្ជីអប្បបរមារបស់ធនាគារមេ ក្នុងករណីចំណាត់ថ្នាក់របស់ធនាគារមេធ្លាក់ចុះក្រោមចំណាត់ថ្នាក់វិនិយោគ
- លិខិតបញ្ជាក់របស់ធនាគារមេដែលបញ្ជាក់អំពីការបញ្ជូនលិខិតធានាជូនអាជ្ញាធរត្រួតពិនិត្យរបស់ធនាគារមេ និង
- ផែនការនិងយុទ្ធសាស្ត្របង្កើនដើមទុនតាមដំណាក់កាលដែលអនុម័តដោយក្រុមប្រឹក្សាភិបាលនៃធនាគារមេឬដោយអ្នកដែលបានទទួលសិទ្ធិពីក្រុមប្រឹក្សាភិបាលនៃធនាគារមេដើម្បីបង្កើនដើមទុនស្របតាមការកំណត់នៃប្រកាសស្តីពីដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

សាខាធនាគារបរទេស ត្រូវផ្ញើលិខិតបញ្ជាក់អំពីចំណាត់ថ្នាក់វិនិយោគរបស់ធនាគារមេ ដែលនៅមានសុពលភាព និងមានការបញ្ជាក់ភាពត្រឹមត្រូវមកធនាគារជាតិនៃកម្ពុជាឲ្យបានទៀងទាត់ក្នុងសប្តាហ៍ទីមួយនៃខែមករា និងខែកក្កដា រៀងរាល់ឆ្នាំ ឬតាមការចាំបាច់ ។ លើសពីនេះទៀត សាខាធនាគារបរទេសត្រូវរាយការណ៍ជាបន្ទាន់មកធនាគារជាតិនៃកម្ពុជា ប្រសិនបើភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិបន្ថយចំណាត់ថ្នាក់របស់ធនាគារមេ ។

ធនាគារមេត្រូវមានលិខិតធានាអំពីការបង្កើនដើមទុនចុះបញ្ជីអប្បបរមាក្នុងករណីចំណាត់ថ្នាក់របស់ធនាគារមេធ្លាក់ចុះក្រោមចំណាត់ថ្នាក់វិនិយោគ ។ លិខិតធានាបង្កើនដើមទុននេះ ត្រូវមានចែងពីការផ្តល់ដើមទុនបន្ថែមនៅក្នុងរយៈពេល១០ (ដប់) ថ្ងៃធ្វើការ និងត្រូវភ្ជាប់មកជាមួយនូវសេចក្តីសម្រេចបង្កើនដើមទុនរបស់ក្រុមប្រឹក្សាភិបាលនៃធនាគារមេ ។ សំណុំឯកសារបង្កើនដើមទុនត្រូវផ្ញើជូនធនាគារជាតិនៃកម្ពុជា ក្នុងរយៈពេល៣០ថ្ងៃចាប់ពីថ្ងៃផ្ទេរដើមទុន ។ ធនាគារមេត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីពីកាតព្វកិច្ចធានាបង្កើនដើមទុនខាងលើ ទៅអាជ្ញាធរត្រួតពិនិត្យប្រទេសដើម ។

**៣.២ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្សេងទៀត ត្រូវផ្តល់ឯកសារដូចខាងក្រោម ៖**

- ច្បាប់ចម្លងនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល អំពីការបង្កើនដើមទុនចុះបញ្ជីអប្បបរមា
- ច្បាប់ចម្លងនៃសេចក្តីសម្រេចរបស់ភាគទុនិក អំពីការបង្កើនដើមទុនចុះបញ្ជីអប្បបរមា
- លិខិតធានាពីភាគទុនិកមានឥទ្ធិពល អំពីការបង្កើនដើមទុនចុះបញ្ជីអប្បបរមា និង
- ផែនការ និងយុទ្ធសាស្ត្របង្កើនដើមទុនតាមដំណាក់កាល ដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ដើម្បីបង្កើនដើមទុនចុះបញ្ជីអប្បបរមា ស្របតាមការកំណត់នៃប្រកាសស្តីពីដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

## ៤. វិធានការផ្សេងទៀត

ក្នុងករណី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនមានលទ្ធភាពបំពេញតាមខ្លឹមសារនៃប្រកាសស្តីពីដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គ្រឹះស្ថានត្រូវជ្រើសរើសយកដំណោះស្រាយណាមួយដូចខាងក្រោម ៖

- ការស្វែងរកវិនិយោគិនថ្មីដែលមានសក្តានុពល
- ការរំលាយក្រុមហ៊ុនបញ្ចូលគ្នាជាមួយគ្រឹះស្ថានដទៃទៀត
- ការផ្លាស់ប្តូររូបភាពគតិយុត្តរបស់គ្រឹះស្ថាន
- ការជំរះបញ្ជីដោយស្ម័គ្រចិត្ត ។

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបំពេញសំណុំឯកសារពាក់ព័ន្ធនឹងដំណោះស្រាយដែលបានជ្រើសរើស ជូនធនាគារជាតិនៃកម្ពុជា ។

## ៥. ប្រសិទ្ធភាពអនុវត្ត

សារាចរណែនាំលេខ ធ៧-០១០-០០១ ស.រ.ណ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១០ ស្តីពី ការកំណត់ចំណាត់ថ្នាក់វិនិយោគ ត្រូវចាត់ទុកជានិរាករណ៍ ។

សារាចរណែនាំនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសាភិបាល**

**ជា.ចាន់តូ**